# ពិនិត្យមើលឲ្យប្រាកដ!

# ប្រាក់បៀវត្សអប្បរមា



ទាំងអ្នកធ្វើការងារ ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ
កុំភ្លេចពិនិត្យមើល

## ខេត្តអ៊ីបារ៉ាគិ យូ ប្រាក់បៀវត្សអប្បបរមា

ចាប់ពីថ្ងៃទី 12 ខែតុលា ឆ្នាំ2025 នេះតទៅ
ចំនួនទឹកប្រាក់ក្នុងមួយម៉ោង

# 1,074 យ៉េន

ធៀបនឹងឆ្នាំមុន UP
69 យ៉េន

カンボジア語版

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

ឆែកតាម WEB!
វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បបរមា
(មានតែភាសាជប៉ុន)
最低賃金　特設サイト　検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា សូមទាក់ទងមកមន្ទីរការងារខេត្តអ៊ីបារ៉ាគិ ឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត។
茨城労働局　検索

វេបសាយពិសេសអំពីការដំឡើងប្រាក់ឈ្នួល
(មានតែភាសាជប៉ុន)
មានផ្សព្វផ្សាយអំពីគោលនយោបាយគាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។
賃金引上げ特設ページ　検索

ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

業務改善助成金
ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន



ក្រសួងសុខាភិបាល ការងារនិងសុខុមាលភាព



# ទាំងអ្នកធ្វើការងារ ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ។ ពិនិត្យមើលកុំខាន ប្រាក់បៀវត្សអប្បបរមា!

"ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា" ត្រូវអនុវត្តចំពោះអ្នកធ្វើការងារទាំងអស់ ទោះបីមានអាយុ ឬរបៀបធ្វើការខុសគ្នាដូចជា ការងារមិនពេញម៉ោង ឬសិស្សនិស្សិតជាដើមក៏ដោយ។ សូមបំពេញប្រាក់បៀវត្សដែលចង់ឆែក(*1) និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តនៃកន្លែងធ្វើការ ចូលតារាងប្រៀបធៀប រួចប្រៀបធៀបវា!(*2)

## វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

**A អ្នកដែលមានប្រាក់ខែតាមម៉ោង**

ប្រាក់ខែតាមម៉ោង ______ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ______ យ៉េន

**B អ្នកដែលមានប្រាក់ខែតាមថ្ងៃ**

ប្រាក់ខែតាមថ្ងៃ ______ យ៉េន ÷ ចំនួនម៉ោងធ្វើការកំណត់ជាមធ្យមក្នុងមួយថ្ងៃ ______ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ______ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ______ យ៉េន

**C អ្នកដែលមានប្រាក់ខែតាមខែ**

ប្រាក់ខែតាមខែ ______ យ៉េន ÷ ចំនួនម៉ោងធ្វើការកំណត់ជាមធ្យមក្នុងមួយខែ ______ ម៉ោង = ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ______ យ៉េន ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ______ យ៉េន

**D អ្នកដែលរួមបញ្ចូលគ្នាចំណុច A B និង C ខាងលើ**

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមនៅលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

① ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា B
② ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា C
③ ចំនួនទឹកប្រាក់សរុបដែលបូក ① និង ② ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖
① ប្រាក់បៀវត្សដែលទូទាត់បណ្ដោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើស១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ
(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធភាពស្នាដៃ សូមទាក់ទងមកមន្ទីរការងារឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត

**業務改善助成金**

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុត ត្រឹម 600 ម៉ឺនយ៉េន

## លោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

### តោះនាំគ្នាប្រើ "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ដែលគាំទ្រការដំឡើងប្រាក់បៀវត្ស!



## អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ?

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ជំនួយដល់សហគ្រាសតូចនិងមធ្យម និងប្រតិបត្តិករអាជីវកម្មខ្នាតតូច ដែលមានគោលដៅបង្កើនផលិតភាពនិងដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម (ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)"។ ក្នុងករណីដែលបានធ្វើការវិនិយោគលើសម្ភារៈជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ។

**មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទអំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច**

0120-366-440

**ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)**

業務改善助成金 検索

### លក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ

- ☑ ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
- ☑ ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
- ☑ ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
- ☑ គ្មានមូលហេតុនៃការមិនផ្តល់ការឧបត្ថម្ភដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

**ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម**

ពិនិត្យមើលទិដ្ឋភាពទូទៅតាមវីដេអូ!

### ជំហានរហូតដល់ការផ្តល់ប្រាក់ឧបត្ថម្ភ

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភនិងផែនការអនុវត្តគម្រោងជាដើម ទៅមន្ទីរការងារនៃរាជធានីខេត្តដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ

ត្រួតពិនិត្យ

2. ក្រោយសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានដាក់ពាក្យមក
3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្តនិងពាក្យស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភទៅមន្ទីរការងារ

ត្រួតពិនិត្យ

4. ផ្តល់ឲ្យ

ពិនិត្យមើលបែបបទតាមវីដេអូ!

## ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស សូមប្រឹក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援センター 検索

## មូលនិធិគាំទ្រកំណែទម្រង់របៀបធ្វើការ

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្តល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援資金 検索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。

(R7.9)